ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

លេខ : ៣៨១ ដនស

## សារលិខិតជូនពរ
## សម្តេចធម្មវិសុទ្ធវង្សា សៅ ទី ហេងសំរិន

ក្នុងឱកាសដ៏មហានក្ខត្តឫក្សចម្រើនអាយុវឌ្ឍនមង្គលរបស់ **សម្តេចធម្មវិសុទ្ធវង្សា** គម្រប់ ៨៦ឆ្នាំ ឈានចូល ៨៧ឆ្នាំ យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្នុងនាមខ្ញុំផ្ទាល់និងភរិយា សូមសម្តែងនូវមនោសញ្ចេតនាគោរពជូននូវសព្ទសាធុការពរជូនចំពោះ **សម្តេចធម្មវិសុទ្ធវង្សា** សូមប្រកបដោយសុខភាពល្អបរិបូរណ៍ កម្លាំងពលំមាំមួន បញ្ញាញាណភ្លឺថ្លាវាងវៃ និងជន្មាយុយឺនយូរ ដើម្បីបន្តគាំទ្រដល់ការដឹកនាំរបស់រាជរដ្ឋាភិបាល ក្នុងបុព្វហេតុដ៏ថ្លៃថ្លានៃការការពារខឿនឯករាជ្យជាតិ បូរណភាពទឹកដី សុខសន្តិភាព ការបង្រួបបង្រួមជាតិ ការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងការអភិវឌ្ឍប្រទេសជាតិ ជាពិសេសក្នុងការបម្រើឧត្តមប្រយោជន៍ជាតិ សាសនា ព្រះមហាក្សត្រ តាមរយៈការបរិច្ចាគទ្រព្យសម្បត្តិផ្ទាល់ខ្លួនដោយសទ្ធាជ្រះថ្លាក្នុងការស្ថាបនាសមិទ្ធផលនានា បូជាថ្វាយព្រះពុទ្ធសាសនាក្នុងវិស័យពុទ្ធចក្រនិងអាណាចក្រ ប្រកបដោយសប្បុរសធម៌ សង្គហធម៌ និងមនុស្សធម៌ដ៏ខ្ពង់ខ្ពស់វិសេសវិសាលក្រៃលែង ដោយឈរលើស្មារតីពូនជ្រំនូវមរតកដ៏ថ្លៃថ្លាបំផុតរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ "ព្រះបរមរតនកោដ្ឋ"** និងគាំទ្រគោលនយោបាយ យុទ្ធសាស្ត្រ និងសមិទ្ធផលនានាដែលកើតចេញពីកិច្ចខិតខំប្រឹងប្រែងរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ បិតាសន្តិភាព** និងបេសកកម្មដ៏មហាបវរថ្លៃថ្លាជាបន្តរបស់ **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី** សម្រាប់ជាឧត្តមប្រយោជន៍ជូនជាតិ និងមាតុភូមិកម្ពុជា។

រាជរដ្ឋាភិបាល ក្រោមការដឹកនាំដ៏ឈ្លាសវៃ ជវភាព និងទស្សនវិស័យទំនើបជឿនលឿនរបស់ **សម្តេចធិបតី នាយករដ្ឋមន្ត្រី**, ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បន្តប្តេជ្ញាឆ្លើយតបនឹងដំណើររបស់កម្ពុជា ពីការកសាងបាននូវឯករាជ្យជាតិ ការរក្សាបាននូវសុខសន្តិភាព ឆ្ពោះទៅការកសាងកម្ពុជាសហសម័យ ប្រកបដោយឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ អព្យាក្រឹត្យ វឌ្ឍនភាពសង្គម ដោយប្រែក្លាយការចុះបញ្ជីដីចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុបង្ហើយ សេវាគាប់ចិត្ត និងបរិយាកាសមិនមានវិវាទ ទៅជាឫសរយាងដើម្បីទ្រទ្រង់ឫសកែវនៃសុខសន្តិភាព។

ក្នុងឱកាសដ៏ប្រសើរថ្លៃថ្លានេះ យើងខ្ញុំទាំងអស់គ្នា សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក ទេវតាថែរក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា គុណព្រះរតនត្រ័យកែវទាំងបី សូមតាមជួយបីបាច់ថែរក្សា និងប្រោះព្រំសព្ទសាធុការពរ សិរីសួស្តី ជ័យមង្គល បវរមហាប្រសើរ ជូន **សម្តេចធម្មវិសុទ្ធវង្សា និង សម្តេចអគ្គមហាពញាចក្រី ព្រាមនាំងបុត្រាបុត្រី ចៅប្រុស ចៅស្រី** ជាទីស្រឡាញ់ សូមប្រកបដោយពុទ្ធពរ និងពរទាំងប្រាំប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចធម្មវិសុទ្ធវង្សា** មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំទាំងអស់គ្នា៕

ថ្ងៃសុក្រ ១៤កើត ខែ មាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**សាយ សំអាល់**

អាសយដ្ឋាន : ដីឡូត៍លេខ ២០០៥ ផ្លូវលេខ ៣០៧ សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរស័ព្ទ (855) 23 886 999 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com